# ៧. ថ្នាក់ទី ៤-៦

៧.១ គោលបំណងនៃកម្មវិធីសិក្សាអប់រំមូលដ្ឋានកំរិតបឋមសិក្សា "ថ្នាក់ទី ៤-៦ " គឺពង្រឹង និង ពង្រីកចំនេះដឹង និងការយល់របស់សិស្សលើផ្នែក ភាសាខ្មែរ គណិតវិទ្យា បំនិនសិក្សា បំនិនជីវិត សីលធម៌ និង ការអភិវឌ្ឍបុគ្គលិក លក្ខណៈដែលអាចអោយសិស្សបន្តការសិក្សាពេញមួយជីវិតបាន ព្រមទាំងចាប់ផ្តើមណែនាំសិស្សលើខ្លឹមសារផ្នែក វិទ្យាសាស្ត្រ និង សិក្សាសង្គម។

៧.២ **កម្មវិធីសិក្សាជាតិ** នៅថ្នាក់ទី ៤-៦ មានមុខវិជ្ជាសិក្សា និង បំនែងចែកម៉ោងសិក្សាតាមមុខវិជ្ជានីមួយៗ ដែលមួយម៉ោងសិក្សាមានរយៈពេល ៤០នាទី ដូចខាងក្រោម :

| **មុខវិជ្ជាកម្មវិធីសិក្សាជាតិ** | **ចំនួនម៉ោងសិក្សាក្នុង១សប្តាហ៍** | |
|---|---|---|
| | **ថ្នាក់ទី ៤** | **ថ្នាក់ទី ៥ - ៦** |
| ភាសាខ្មែរ | ១០ | ៨ |
| គណិតវិទ្យា | ៦ | ៦ |
| វិទ្យាសាស្ត្រ | ៣ | ៤ |
| សិក្សាសង្គម (រួមទាំងអប់រំសិល្បៈ) | ៤ | ៥ |
| អប់រំកាយ កីឡា និង សុខភាព | ២ | ២ |
| **សរុបម៉ោងសិក្សាកម្មវិធីសិក្សាជាតិ** | **២៥** | **២៥** |
| កម្មវិធីបំនិនជីវិតតាមមូលដ្ឋាន | ២-៥ | ២-៥ |
| **សរុបម៉ោងសិក្សា** | **២៧-៣០** | **២៧-៣០** |

៧.៣ ការអប់រំសិល្បៈ (ចំរៀង គំនូរ របាំ តន្ត្រី ...) ត្រូវបញ្ចូលក្នុងមុខវិជ្ជាសិក្សាសង្គម ។

7.4 នៅថ្នាក់ទី៥ និង ទី៦ភាសាបរទេសត្រូវបង្រៀនដល់សិស្សតាមលទ្ធភាពសាលារៀន។ ក្នុងដំនាក់កាលទី១(២០០៥-២០០៩) ក្រសួងអ.យ.ក. នឹងជំរុញ សាលារៀនអោយបង្រៀនភាសាបរទេសដោយប្រើធនធានឧបត្ថម្ភពីខាងក្រៅ និងប្រើម៉ោងក្នុងកម្មវិធីបំនិនជីវិតតាមមូលដ្ឋាន។